**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ.....................ន. គ. ស .......

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសក្រុមហ៊ុនជំនាញបច្ចេកវិទ្យាព័ត៌មាននិងគណនេយ្យ លើការអភិវឌ្ឍន៍ថ្នាលរបាយការណ៍ហិរញ្ញវត្ថុឌីជីថល សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) គឺជាស្ថាប័នតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស.** បានដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល១០ឆ្នាំ (២០២១ -២០៣០) និងផែនការសកម្មភាពក្នុងគោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨។ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរិមាពីបរវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងការផ្តល់កាលានុវត្តភាពសំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក **ន.គ.ស.** ត្រូវការជ្រើសរើសក្រុមហ៊ុនជំនាញបច្ចេកវិទ្យាព័ត៌មាននិងគណនេយ្យ ដើម្បីផ្តល់សេវាអភិវឌ្ឍន៍ថ្នាលរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូច និងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ក្នុងគោលដៅលើកកម្ពស់តម្លាភាព និងភាពអាចទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ និងលើកកម្ពស់កម្រិតអនុលោមភាព។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសក្រុមហ៊ុនជំនាញបច្ចេកវិទ្យាព័ត៌មាននិងគណនេយ្យ ដែលមានគុណវុឌ្ឍិដូចខាងក្រោម÷

## ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុនដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មពេញលេញ
- អ្នកដឹកនាំជាន់ខ្ពស់ត្រូវមានសញ្ញាបត្រគណនេយ្យករជំនាញ (ACCA/CPA)
- ជាប្រភេទក្រុមហ៊ុនផ្តល់សេវាបច្ចេកវិទ្យាព័ត៌មាននិងគណនេយ្យដែលមានស្នាដៃ បទពិសោធន៍ និងមានចំណេះដឹងច្បាស់លាស់ពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្មក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគណនេយ្យឌីជីថល សម្រាប់ក្រុមហ៊ុនក្នុងស្រុកនិងក្រុមហ៊ុនអន្តរជាតិ ដែលមានរយៈពេលយ៉ាងតិចចាប់ពី៨ (ប្រាំបី)ឆ្នាំឡើងទៅ
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគណនេយ្យឌីជីថលសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងស្រុក និងអន្តរជាតិ
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគណនេយ្យឌីជីថលសម្រាប់ស្ថាប័នរដ្ឋ
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

## ២. លក្ខខណ្ឌយោងការងារ

- ត្រូវអភិវឌ្ឍថ្នាលរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមានលក្ខណៈស្តង់ដាបច្ចេកវិទ្យាខ្ពស់
- ត្រូវអភិវឌ្ឍនូវមុខងារសំខាន់ៗក្នុងការទ្រទ្រង់ថ្នាលរបាយការណ៍ឌីជីថល ដែលក្នុងនោះរួមមាន÷ ១) តារាងគណនីរួមដែលមានប្រភេទគណនី ជំពូកគណនី និងអនុគណនី ២) ទម្រង់របាយការណ៍ហិរញ្ញវត្ថុស្តង់ដា ៣) ឧបករណ៍បម្លែងរូបិយបណ្ណ និងអត្រាប្តូរប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ៤) ការត្រួតពិនិត្យអនុលោមភាពដោយស្វ័យប្រវត្តិ ៥) គ្រប់គ្រងការដាក់របាយការណ៍ប្រចាំឆ្នាំ ៦) ការវិភាគគោល ៧) និង API សម្រាប់ភ្ជាប់ជាមួយប្រព័ន្ធគណនេយ្យដែលត្រូវអនុម័តឱ្យភ្ជាប់
- ត្រូវអភិវឌ្ឍទម្រង់រួមបែបឌីជីថល និងទិន្នន័យដែលមានលក្ខណៈស្តង់ដាដោយផ្អែកតាមប្រព័ន្ធវត្ថុករសាស្ត្រ ដើម្បីសម្រួលដំណើរការក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាជាតិ និងអន្តរជាតិ
- ត្រូវធានាឱ្យមានអន្តរប្រតិបត្តិការជាមួយប្រព័ន្ធរបាយការណ៍ជាសកលដោយផ្អែកតាមបច្ចេកសព្ទឌីជីថលគណនេយ្យរបស់ស្តង់ដារបាយការណ៍អន្តរជាតិ
- ត្រូវរៀបចំនូវសៀវភៅណែនាំការប្រើប្រាស់ថ្នាល និងការណែនាំជាជំហាននៅក្នុងថ្នាលឌីជីថលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សំគាល់
- ត្រូវផ្តល់សេវាថែទាំ (Maintenance) ដែលនឹងត្រូវកំណត់ក្នុងកិច្ចសន្យា
- ត្រូវផ្តល់នូវការបណ្តុះបណ្តាលលើការប្រើប្រាស់ថ្នាលរបាយការណ៍ហិរញ្ញវត្ថុឌីជីថល ជូនមន្ត្រី **ន.គ.ស.** និងអ្នកប្រើប្រាស់
- អនុវត្តការងារពាក់ព័ន្ធផ្សេងទៀត តាមការស្នើសុំរបស់អគ្គនាយកនៃ **ន.គ.ស.**។

## ៣. កម្រៃ

កម្រៃសម្រាប់ការអភិវឌ្ឍន៍ថ្នាលរបាយការណ៍ហិរញ្ញវត្ថុឌីជីថលគឺបើកចំហរសម្រាប់ការចរចា។

## ៤. រយៈពេលសម្រាប់ការអភិវឌ្ឍន៍ថ្នាល

ការអភិវឌ្ឍន៍ថ្នាលរបាយការណ៍ហិរញ្ញវត្ថុឌីជីថលខាងលើនេះមានរយៈពេលមិនលើស៤ (បួន) ខែ។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងការអភិវឌ្ឍន៍លើស៤ (បួន) ខែ នឹងត្រូវមានការពិភាក្សានិងចរចា។ កិច្ចសន្យាមួយ នឹងត្រូវបង្កើតឡើងរវាង **ន.គ.ស** ជាមួយនឹងក្រុមហ៊ុនដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

## ៥. ការដាក់ពាក្យ

ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ សូមផ្ញើរសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh ត្រឹមថ្ងៃទី១៧ ខែមិថុនាឆ្នាំ២០២៤ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ÷ ០៦៩ ៧៨៣ ៩៣៦ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**